# ក្រុមហ៊ុន ជីន ហ្វេង ដា (ខេមបូឌា) ព្រីនធីង ឯ.ក

**JIN FENG DA (CAMBODIA) PRINTING CO.,LTD**

អាស័យដ្ឋាន: #២៥៦ ផ្លូវ គ្មាន ភូមិ ព្រៃពពេល សង្កាត់ សំរោងក្រោម ខណ្ឌ ពោធិ៍សែនជ័យ រាជធានីភ្នំពេញ

## កំណត់ហេតុព្រមព្រៀង

## ស្តីពីការព្យួរកិច្ចសន្យាការងារ

ឆ្នាំពីរពាន់ម្ភៃបី ខែ ធ្នូ ថ្ងៃទី១៨ វេលាម៉ោង ០៩:០០ នាទីតំណាងក្រុមហ៊ុន និងតំណាងកម្មករ តំណាងប្រធានក្រុម មានការប្រជុំពិភាក្សាគ្នាស្តីពីការព្យួរកិច្ចសន្យាការងារ ចំនួន ៣២ថ្ងៃ ចាប់ពីថ្ងៃទី២៥ ខែ ធ្នូ ឆ្នាំ២០២៣ ដល់ថ្ងៃទី២៥ ខែ មករា ឆ្នាំ២០២៤ លើកម្មករនិយោជិតចំនួន ៣៥ នាក់ (ស្រី ២១ នាក់ ) ក្នុងចំណោមកម្មករនិយោជិតសរុបចំនួន ១០៤ នាក់ (ស្រី ៥៧ នាក់ ) ។

ដោយសារបច្ចុប្បន្នពិភពលោក នៅតែបន្តរងផលប៉ះពាល់ដោយសារវិបត្តិសេដ្ឋកិច្ច វិបត្តិសង្គ្រាម និងការបម្រែបម្រួលសេដ្ឋកិច្ចពិភពលោក ធ្វើអោយអតិថិជនដែលជាអ្នកបញ្ជាទិញទំនិញ

ផលិតផលសំលៀកបំពាក់ របស់ក្រុមហ៊ុនត្រូវបានកាត់បន្ថយការបញ្ជាទិញយ៉ាងច្រើន ដែលជាហេតុធ្វើអោយក្រុមហ៊ុនមិនមានទំនិញគ្រប់គ្រាន់ក្នុងការផ្តល់ការងារជូនបងប្អូនកម្មករនិយោជិតទាំងអស់នោះឡើយ ។ ហេតុដូច្នោះក្រុមហ៊ុនមានតែស្នើសុំព្យួរកិច្ចសន្យាការងារដើម្បីបន្តជំហរនិងរក្សាលំនឹងការងារ រង់ចាំស្ថានការណ៍ត្រឡប់មកដូចដើមវិញ នោះទើបអាចដំណើរការងារធម្មតាវិញ ។

## ភាគីទាំងសងខាងបានឯកភាពព្រមព្រៀងដូចខាងក្រោម:

-ភាគីខាងក្រុមហ៊ុនអនុវត្តតាមសេចក្តីណែនាំ លេខៈ ០២០/២៣ ក.ប/ស.ណ.ន.ខ.ល របស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ចុះថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០២៣ ។

-ភាគីខាងក្រុមហ៊ុនឯកភាពផ្តល់ជូនប្រាក់ឧបត្ថម្ភចំនួន ៤៥ដុល្លា សម្រាប់ការព្យួរកិច្ចសន្យាការងារ ។

-ភាគីខាងក្រុមហ៊ុននិងបើកប្រាក់ឧបត្ថម្ភជូនកម្មករនៅថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០២៣។

ថ្ងៃចន្ទ ៦ កើត ខែមិគសិរ ឆ្នាំថោះ បញ្ចស័ក ពុទ្ធសករាជ ២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០២៣

១.អ៊ុក ថៃល ២.គង់ សុមានីន ៣.ស៊ិត បំព្រុង

៤.អាត ស្រីភីនន ៥.ស៊ិន ចន្ទី ៦.អ៊ុក សាវី

នាយកក្រុមហ៊ុន

ព្រះរាជាណាចក្រកម្ពុជា
ក្រុមហ៊ុន ជីន ហ្វេង ដា (ខេមបូឌា) ព្រីនធីង ឯ.ក
JIN FENG DA (CAMBODIA) PRINTING CO., LTD.
KINGDOM OF CAMBODIA

ZHOU BO